ធនាគារជាតិ នៃ កម្ពុជា
លេខ ធ៧៣.០២៤.១២៨៦.ឆ.ន.ស.ល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤*

# សេចក្ដីបដិសេធ

ធនាគារជាតិនៃកម្ពុជា សូមបដិសេធទាំងស្រុងចំពោះក្រុមឆាណែល ឬគណនីតេលេក្រាម (Telegram) ឬបណ្ដាញទំនាក់ទំនងសង្គមផ្សេងៗទៀត ដែលបានប្រើប្រាស់និម្មិតសញ្ញា និងឈ្មោះ ធនាគារជាតិនៃកម្ពុជា ក្នុងចេតនាទុច្ចរិត ឆបោកប្រាក់កាសតាមរយៈការផ្សព្វផ្សាយពីគម្រោងវិនិយោគ ឬប្រតិបត្តិការជួញដូរផលិតផលហិរញ្ញវត្ថុក្រៅផ្លូវការ ដូចជា ហាងឆេងមាស អត្រាប្ដូរប្រាក់ ឬទ្រព្យឌីជីថល ជាដើម។

ធនាគារជាតិនៃកម្ពុជា សូមបញ្ជាក់សារជាថ្មីថា ធនាគារជាតិនៃកម្ពុជា មិនមានក្រុមឆាណែល ឬគណនីតេលេក្រាមផ្លូវការទេ ហើយក៏មិនធ្លាប់ប្រើប្រាស់បណ្ដាញទំនាក់ទំនងសង្គមផ្សេងៗទៀត សម្រាប់ផ្សព្វផ្សាយឱ្យសាធារណជនចូលរួមវិនិយោគលើទីផ្សារហិរញ្ញវត្ថុឡើយ។

ធនាគារជាតិនៃកម្ពុជា សូមអំពាវនាវ និងក្រើនរំលឹកដល់សាធារណជនឱ្យបង្កើនការប្រុងប្រយ័ត្ន ខ្ពស់ជាប់ជាប្រចាំ ដើម្បីកុំឱ្យចាញ់បោកល្បិចកលជនទុច្ចរិតមួយចំនួន ដែលអាចនាំឱ្យបាត់បង់ប្រាក់កាស ឬទ្រព្យសម្បត្តិផ្សេងៗ តាមរយៈការចូលរួមវិនិយោគ ជាមួយក្រុមទាំងឡាយណាដែលពុំមានអាជ្ញាប័ណ្ណ និងការត្រួតពិនិត្យត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច។

សូមអរគុណ!

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh

**បណ្ដាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA